ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ ១១៤ គ.ជ.ប

ថ្ងៃសៅរ៍ ២កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៨

សេចក្តីប្រកាសព័ត៌មាន
ថ្ងៃទី០៨ នៃយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

ថ្ងៃនេះទី១៤ ខែកក្កដា ឆ្នាំ២០១៨ ត្រូវជាថ្ងៃទី០៨ នៃការឃោសនារកសំឡេងឆ្នោត គណបក្សនយោបាយនីមួយៗបានធ្វើសកម្មភាពឃោសនា នៅតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

- **ខេត្តត្បូងឃ្មុំ ៖**
  - គណបក្ស យុវជនកម្ពុជា បានធ្វើសកម្មភាពហែក្បួនឆ្លងកាត់ ស្រុកត្បូងឃ្មុំ ពញាក្រែក ទៅស្រុកមេមត់ ដោយមានអ្នកចូលរួម ៥៨៥នាក់ រថយន្ត ២៣គ្រឿង និងម៉ូតូ ៤៣គ្រឿង។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពហែក្បួន កាត់ស្រុកត្បូងឃ្មុំ ទៅស្រុកអូរាំងឪ និងត្រឡប់មកក្រុងសួងវិញ ដោយមានអ្នកចូលរួមសរុប ៥៣៣នាក់ រថយន្ត ៣១គ្រឿង និងម៉ូតូ ១១៣គ្រឿង។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រជុំឃោសនា នៅស្រុកពញាក្រែក ស្រុកតំបែរ និងប្រជុំផ្សព្វផ្សាយ និងចាក់មេក្រូចល័តនៅទីស្នាក់ការបក្សឃុំ មួយចំនួនក្នុងស្រុកមេមត់ ក្រូចឆ្មារ និងស្រុកអូរាំងឪ និងចែកខិត្តប័ណ្ណ ដោយមានអ្នកចូលរួមសរុប ២,៧៧២នាក់ រថយន្ត ១៦២គ្រឿង ម៉ូតូ ៦៦២គ្រឿង។
  - គណបក្ស ហ៊ុនសុិនបុិច បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ និងចាក់មេក្រូចល័ត នៅឃុំដូនតី និងឃុំអញ្ចើម។
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាពចែកខិត្តប័ណ្ណនៅឃុំមួយចំនួន ក្នុងស្រុកមេមត់។
- **ខេត្តកំពង់ធំ ៖**
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពជួបប្រជុំ ចាក់មេក្រូចល័ត ដើរចែកខិត្តប័ណ្ណ និងបញ្ចាំងភាពយន្ត សម្តែងសិល្បៈ ចាក់ធុងបាស់ ដោយមានអ្នកចូលរួមសរុប ៧,៤០៧នាក់ រថយន្ត ៧៤គ្រឿង ម៉ូតូនិងកង់ ១,១៦១គ្រឿង និងជលយាន ២៣គ្រឿង។
  - គណបក្ស ហ៊ុនសុិនបុិច បានធ្វើសកម្មភាពជួបប្រជុំ ចាក់មេក្រូចល័ត និងដើរចែកខិត្តប័ណ្ណ ដោយមានអ្នកចូលរួមសរុប ២,៧០៣នាក់ រថយន្ត ២០គ្រឿង ម៉ូតូនិងកង់ ៦៧១គ្រឿង ម៉ូតូកង់បី និងគោយន្ត ៧គ្រឿង និងជលយាន ៣គ្រឿង។

- គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពហែក្បួនដោយមានអ្នកចូលរួមសរុប ៨៦នាក់ រថយន្ត ៤គ្រឿង ម៉ូតូនិងកង់ ៣១គ្រឿង និងម៉ូតូកង់បី ២គ្រឿង ។
- គណបក្ស ខ្មែររួបរួមជាតិ បានធ្វើសកម្មភាពជួបប្រជុំ ចាក់មេក្រូចល័ត និងដើរចែកខិត្តប័ណ្ណ ដោយមានអ្នកចូលរួមសរុប ៤៦៤នាក់ រថយន្ត ៣គ្រឿង ម៉ូតូនិងកង់ ១១៣គ្រឿង ម៉ូតូកង់បី និងគោយន្ត ៤ គ្រឿង ។
- គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាពជួបប្រជុំ ចាក់មេក្រូចល័ត និងដើរចែកខិត្តប័ណ្ណ ដោយមានអ្នកចូលរួមសរុប ១៣០នាក់ ម៉ូតូនិងកង់ ៧០គ្រឿង ម៉ូតូកង់បី និងគោយន្ត ៣គ្រឿង ។
- គណបក្ស ខ្មែរឈប់ក្រ បានធ្វើសកម្មភាពដើរចែកខិត្តប័ណ្ណ ។
- គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន ខ្មែរតែមួយ និងគណបក្ស ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច បានធ្វើសកម្មភាពជួបប្រជុំ ចាក់មេក្រូចល័ត និងដើរចែកខិត្តប័ណ្ណ។

- **ខេត្តកំពង់ឆ្នាំង ៖**
  - គណបក្ស ខ្មែររួបរួមជាតិ និងគណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ តាមភូមិ និងឃុំ។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្ស ហ៊ុនស៊ុនប៊ុច បានធ្វើសកម្មភាពប្រជុំនៅផ្ទះសកម្មជន ចែកខិត្តប័ណ្ណតាមភូមិ ក្នុងឃុំ។
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាពប្រគុំតន្ត្រីនៅទីស្នាក់ការបក្ស។
- **ខេត្តកំពង់ស្ពឺ ៖**
  - គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាពហែក្បួនឃោសនា ដោយមានអ្នកចូលរួមសរុប ២៣៥នាក់ រថយន្ត ១០គ្រឿង ម៉ូតូ ១០០គ្រឿង និងម៉ូតូកង់បី ៣០គ្រឿង។
  - គណបក្ស ហ៊ុនស៊ុនប៊ុច ប្រជាធិបតេយ្យមូលដ្ឋាន និងគណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមភូមិ ។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រជុំឃោសនា នៅស្រុកឱរ៉ាល់ ស្រុកបសេដ្ឋ ស្រុកភ្នំស្រួច ក្រុងច្បារមន ចាក់មេក្រូតាមទីស្នាក់ការគណបក្សឃុំ និងចែកខិត្តប័ណ្ណតាមខ្នងផ្ទះ ដោយមានអ្នកចូលរួមសរុប ២៤,៨៩១នាក់ ។
- **ខេត្តកែប ៖**
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពចាក់មេក្រូ នៅទីស្នាក់ការបក្សខេត្ត ទីស្នាក់ការភូមិ និងចាក់មេក្រូចល័តតាមផ្ទះប្រជាពលរដ្ឋ ចែកខិត្តប័ណ្ណ និងបង្រៀនគូសសន្លឹកឆ្នោត។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពចាក់មេក្រូនៅផ្ទះលោក គង់ ស៊ីណា ។
- **ខេត្តស្វាយរៀង ៖**
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពចាក់មេក្រូ ចែកខិត្តប័ណ្ណ នៅឃុំច្រេស ឃុំជ្រុងពពេល និងឃុំអំពិល និងណែនាំគូសសន្លឹកឆ្នោត។
  - គណបក្ស ហ៊ុនស៊ុនប៊ុច សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ និងគណបក្ស ខ្មែររួបរួមជាតិបានធ្វើសកម្មភាពចាក់មេក្រូនៅទីស្នាក់ការបក្ស ។
  - គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាពចាក់មេក្រូចល័ត និងចែកខិត្តប័ណ្ណ នៅតាមបណ្តាភូមិ ក្នុងឃុំត្រពាំងស្តៅ ស្រុករមាសហែក។

- គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រជុំឃោសនានៅក្រុងបាវិត ស្រុកចន្ទ្រា កំពង់រោទ៍ រំដួល រមាសហែក ស្វាយជ្រុំ និងស្រុកស្វាយទៀប ក្រុងស្វាយរៀង ដោយមានអ្នកចូលរួមសរុប ៤,០៧២នាក់ ចាក់មេក្រូចល័ត ចែកខិត្តប័ណ្ណ និងណែនាំរបៀបគូសសន្លឹកឆ្នោត តាមខ្នងផ្ទះ។

- **រាជធានីភ្នំពេញ ៖**
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាពហែក្បួនឃោសនា ដោយមានអ្នកចូលរួមសរុប ១០០នាក់ រថយន្ត ២០គ្រឿង ម៉ូតូ ១០គ្រឿង និងម៉ូតូកង់បី ១០គ្រឿង។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពហែក្បួនឃោសនា ដោយមានអ្នកចូលរួមសរុប ២០,០០០នាក់ រថយន្ត ១០០គ្រឿង និងម៉ូតូ ៩,០០០គ្រឿង។
  - គណបក្សខ្មែរក្រោក បានធ្វើសកម្មភាពហែក្បួនឃោសនា ដោយមានអ្នកចូលរួមសរុប ១,០០០នាក់ រថយន្ត ១០០គ្រឿង ម៉ូតូ ២០០គ្រឿង និងម៉ូតូកង់បី ៥០គ្រឿង។
  - គណបក្ស ហ៊ុនស៊ុនប៊ិច បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ និងចាក់មេក្រូចល័ត ក្នុងខណ្ឌ៧មករា ទួលគោក ចំការមន មានជ័យ ពោធិ៍សែនជ័យ និងខណ្ឌច្បារអំពៅ ។
  - គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ និងចាក់មេក្រូចល័តនៅខណ្ឌទាំង ១២។
  - គណបក្ស ឆន្ទៈខ្មែរ បានធ្វើសកម្មភាពចាក់មេក្រូ និងចែកខិត្តប័ណ្ណ តាមផ្សារមួយចំនួន ក្នុងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌដង្កោ។
  - គណបក្សខ្មែរតែមួយ និងគណបក្សខ្មែររួបរួមជាតិ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ នៅខណ្ឌឫស្សីកែវ និងខណ្ឌព្រែកព្នៅ។
  - គណបក្ស យុវជនកម្ពុជា បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ នៅបណ្តោយផ្លូវវេងស្រេង(៣៧១) និងផ្លូវទួលពង្រ។

- **ខេត្តកណ្តាល ៖**
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពហែក្បួនក្នុងក្រុងតាខ្មៅ ស្រុកស្អាង និងស្រុកកោះធំ ហើយត្រឡប់មកបញ្ចប់ក្នុងក្រុងតាខ្មៅវិញ ដោយមានអ្នកចូលរួមសរុប ៣,០០០ នាក់ រថយន្ត ៧០គ្រឿង ម៉ូតូ ៥៦០គ្រឿង និងរ៉ឺម៉ក ៥០គ្រឿង។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រមូលផ្តុំប្រជុំឃោសនានៅនឹងកន្លែង ចុះតាមក្រុមបក្ស និងខ្នងផ្ទះ បញ្ចាំងខ្សែភាពយន្ត ប្រគុំតន្ត្រី និងចាក់មេក្រូតាមទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមសរុប ៥៧,២៥៩នាក់ ។
  - គណបក្ស ឆន្ទៈខ្មែរ បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណ ចាក់មេក្រូចល័តតាមក្រុង ស្រុក ក្នុងខេត្ត ។
  - គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណនៅគ្រប់ក្រុង ស្រុកទាំង១១ ក្នុងខេត្ត។
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណនៅគ្រប់ក្រុង ស្រុកទាំង ១១ ក្នុងខេត្ត។
  - គណបក្ស ហ៊ុនស៊ុនប៊ិច បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណ និងចាក់មេក្រូចល័តនៅគ្រប់ក្រុង ស្រុកទាំង១១ ក្នុងខេត្ត។
  - គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណក្នុងខេត្ត។
  - គណបក្ស ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច បានធ្វើសកម្មភាព ចាក់មេក្រូចល័តក្នុងខេត្ត។

- គណបក្ស ខ្មែររួបរួមជាតិ បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណ និងចាក់មេក្រូចល័តក្នុងខេត្ត។

- **ខេត្តពោធិ៍សាត់ ៖**
  - គណបក្ស ខ្មែររួបរួមជាតិ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានធ្វើសកម្មភាពប្រជុំនៅផ្ទះសកម្មជន ចែកខិត្តប័ណ្ណតាមផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស សាធារណរដ្ឋប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស ។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពប្រជុំនៅផ្ទះសកម្មជន ចែកខិត្តប័ណ្ណតាមផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមចំនួនសរុប ១,៤៣៩នាក់។
  - គណបក្ស ខ្មែរឈប់ក្រ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស ហ៊ុនសុិនប៊ិច បានធ្វើសកម្មភាពប្រជុំនៅផ្ទះសកម្មជន ចែកខិត្តប័ណ្ណតាមផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមចំនួនសរុប ៦២៨នាក់។
  - គណបក្ស ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច បានធ្វើសកម្មភាពចែកខិត្តប័ណ្ណតាមខ្នងផ្ទះ និងប្រគុំតន្ត្រីតាមទីស្នាក់ការបក្ស។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រជុំនៅផ្ទះសកម្មជន និងទីសាធារណៈ ចែកខិត្តប័ណ្ណតាមផ្ទះ និងទីសាធារណៈ ដោយមានអ្នកចូលរួមចំនួនសរុប ២០,១៣៨នាក់។

- **ខេត្តកំពត ៖**
  - គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ និងប្រគុំតន្ត្រី ចាក់មេក្រូនៅទីស្នាក់ការបក្ស។
  - គណបក្ស ហ៊ុនសុិនប៊ិច បានធ្វើសកម្មភាពជួបប្រជុំនៅស្រុកអង្គរជ័យ ស្រុកឈូក និងស្រុកបន្ទាយមាស ដោយមានអ្នកចូលរួម ១៥០ នាក់។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពជួបប្រជុំនៅឃុំកោះស្លា ឃុំត្រពាំងភ្លាំង ស្រុកជុំគិរី ដើរចែកខិត្តប័ណ្ណនៅ៤៨៨ភូមិ និងប្រគុំតន្ត្រី និងចាក់មេក្រូនៅទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមសរុប ១៨,០០០នាក់។

- **ខេត្តព្រះសីហនុ ៖**
  - គណបក្ស ហ៊ុនសុិនប៊ិច បានធ្វើសកម្មភាពជួបជុំសកម្មជន នៅទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមសរុប ៥៧នាក់ រថយន្ត ១១គ្រឿង ម៉ូតូ ១២គ្រឿង ចាក់មេក្រូនៅតាមទីស្នាក់ការបក្សក្រុង ស្រុក ឃុំ សង្កាត់។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពប្រជុំឃោសនាជាមួយសកម្មជន ចែកខិត្តប័ណ្ណ ចាក់មេក្រូចល័ត នៅគ្រប់ក្រុង ស្រុក ដោយមានអ្នកចូលរួមសរុប ៩៧នាក់ រថយន្ត ៧គ្រឿង និងម៉ូតូ ៥៧គ្រឿង។

- គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពជួបជុំសកម្មជន នៅទីស្នាក់ការបក្ស ដោយមានអ្នកចូលរួមសរុប ៣០១នាក់ រថយន្ត ១០០គ្រឿង និងម៉ូតូ ៩១គ្រឿង ចាក់មេក្រូនៅតាមទីស្នាក់ការបក្ស ក្រុង ស្រុក ឃុំ សង្កាត់ និងបង្រៀនគូសសន្លឹកឆ្នោត។

- **ខេត្តសៀមរាប ៖**
  - គណបក្ស សញ្ជាតិកម្ពុជា បានធ្វើសកម្មភាពជួបជុំសមាជិកបក្ស នៅអង្គរឃ្សុងយូ ហែក្បួនឃោសនា ឆ្លងកាត់ ស្រុកប្រាសាទបាគង សូទ្រនិគម ស្វាយលើ និងស្រុកបន្ទាយស្រី រួចត្រឡប់មកក្រុងសៀមរាបវិញ ដោយមានអ្នកចូលរួមសរុប ៥០នាក់ រថយន្ត ២គ្រឿង ម៉ូតូកង់បី ២គ្រឿង និងម៉ូតូ ៨គ្រឿង។
  - គណបក្ស ប្រជាជនកម្ពុជា បានធ្វើសកម្មភាពប្រជុំសមាជិកគណបក្សខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ អំពីគោលនយោបាយ និងរបៀបគូសសន្លឹកឆ្នោត ដោយមានអ្នកចូលរួមសរុប ៦,៩២៥នាក់។
  - គណបក្ស ខ្មែរតែមួយ ខ្មែរឈប់ក្រ យុវជនកម្ពុជា និងគណបក្ស ហ៊ុនសុិនប៊ិច បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ ចាក់មេក្រូចល័ត និងជួបសកម្មជនតាមផ្ទះ នៅតាមឃុំ សង្កាត់មួយចំនួនក្នុងខេត្ត។
  - គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពចែកខិត្តប័ណ្ណ ចាក់មេក្រូចល័ត នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដោយមានអ្នកចូលរួមសរុប ២០០នាក់ ម៉ូតូកង់បី ១០០គ្រឿង។
  - គណបក្ស ខ្មែររួបរួមជាតិ បានធ្វើសកម្មភាពចាក់មេក្រូចល័ត និងចែកខិត្តប័ណ្ណនៅសង្កាត់ទាំង ១២ ក្នុងក្រុងសៀមរាប។
  - គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើសកម្មភាពចាក់មេក្រូចល័ត និងចែកខិត្តប័ណ្ណ នៅក្រុងសៀមរាប ស្រុកពួក និងស្រុកប្រាសាទបាគង។

ជារួមបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នាឱកាសឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនៅថ្ងៃទី០៨នេះ ត្រូវបានធានា ហើយការឃោសនាបានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា នៅក្របខ័ណ្ឌទូទាំងប្រទេស។ រហូតមកដល់ថ្ងៃនេះ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត បានទទួលបណ្តឹងចំនួន ៦ករណី ដែលក្នុងនោះ ៥ករណី បានដោះស្រាយរួចរាល់ និង ១ករណីទៀត នៅខេត្តព្រៃវែងកំពុងបន្តនីតិវិធី៕

ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!

ឯកឧត្តម **ហាង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប Tel: (855)12 959 666 Email : hangputhea@gmail.com	ឯកឧត្តម **ឌឹម សុវណ្ណារ៉ុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប Tel: (855)12 518 485 Email : sovannaromhy@yahoo.fr